**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៦ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកំណត់ចំណាយដោយឡែកសំរាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាព នៃការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រជួបការលំបាក សំរាប់ការចូលរៀនដោយសមធម៌នៅមធ្យមសិក្សាបឋមភូមិ

*****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ-បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០២ ស្ដីពីការកំណត់ចំណាយដោយឡែក សំរាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាពនៅក្រសួងអប់រំ យុវជន និង កីឡា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៣

**សំរេច**

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការចំណាយដោយឡែកសំរាប់ការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ស្ដីពីការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រសំរាប់ការចូលរៀនដោយសមធម៌នៅកំរិតមធ្យមសិក្សាបឋមភូមិ ដែលប្រើប្រាស់ថវិការបស់ក្រសួងអប់រំ យុវជន និង កីឡា តែប៉ុណ្ណោះ ។

**មាត្រា ២.-**

ការចំណាយដោយឡែកនេះ ត្រូវអនុវត្តសំរាប់កម្មវិធីសកម្មភាពជាអាទិភាព ដូចមានចែងក្នុងមាត្រា ១ រៀងរាល់ឆ្នាំ ចាប់ពី ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៣ តទៅ ។

**មាត្រា ៣.-**

ប្រាក់ឧបត្ថម្ភផ្ដល់ដល់សិស្សអាហារូបករណ៍ក្រោមកម្មវិធីសកម្មភាពជាអាទិភាព ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ជូនយ៉ាងច្រើន ១៨០.០០០៛ ( មួយរយប៉ែតសិបពាន់រៀលគត់ ) ក្នុងមួយនាក់ ក្នុងឆ្នាំសិក្សានីមួយៗ ដែលមាន ១០ (ដប់)ខែ សំរាប់ការផ្គត់ផ្គង់សំភារៈសិក្សាជាមូលដ្ឋាន សំលៀកបំពាក់ឯកសណ្ឋាន និង មធ្យោបាយធ្វើដំណើរ ។

ការផ្ដល់អាហារូបករណ៍ក្នុងឆ្នាំសិក្សានីមួយៗមានចំនួន ៣ (បី)លើក ស្របតាមឆ្នាំថវិកា ។

**មាត្រា ៤.-**

ក្រសួងអប់រំ យុវជន និង កីឡា ត្រូវធ្វើសារាចរណែនាំ ស្ដីពីការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រសំរាប់ការចូលរៀនដោយសមធម៌នៅមធ្យមសិក្សាបឋមភូមិ ក្នុងការអនុវត្តកម្មវិធីសកម្មភាពជាអាទិភាព ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យតាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៥
- កាលប្បវត្តិ-ឯកសារ